FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ៩ លេខ ៩៨ ខែកក្កដា ឆ្នាំ ២០១០
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ពូជស្រូវធ្ងន់ "ខា ៦"

ពូជស្រូវ "ខា ៦" ជាពូជស្រូវធ្ងន់ដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាចុងឆ្នាំ ១៩៩៥។ បច្ចុប្បន្ន ពូជស្រូវ "ខា ៦" បាននឹងកំពុងពេញនិយមក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ គុណភាពអង្ករល្អ មានភាពថ្លា និងបាយទន់ឆ្ងាញ់ពិសាថែមទៀតផង។

## លក្ខណៈពិសេសៗរបស់ពូជស្រូវ "ខា ៦"

ពូជស្រូវ "ខា ៦" ជាពូជស្រូវធ្ងន់ និងចាប់ចេញផ្កាក្នុងកំឡុងថ្ងៃទី ០៩-១៦ ខែវិច្ឆិកា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កម្ពស់ដើមរបស់ពូជ "ខា ៦" ប្រែប្រួលពី ១២៩-១៧៧ ស.ម និងចំនួនដើមបែកផ្តល់ផល គឺចាប់ពី ៧-៩ ដើមក្នុងមួយគុម្ព អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១៥៥-១៨៨ គ្រាប់ និងមានប្រវែងកួរ ២១-២៤ ស.ម។ ទិន្នផលជាមធ្យមគឺ ៣,៥ តោន ក្នុង ១ ហិកតា និងអាចខ្ពស់ដល់ទៅ ៥ តោនក្នុង ១ ហិកតា។

## វិធីសាស្ត្រដាំដុះ

សម្រាប់ស្រូវសន្ទូង បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី ៣០-៤០ គីឡូក្រាមក្នុងមួយហិកតា ប៉ុន្តែក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និងថែទាំបានល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតា គឺពី ១៥-២០ គីឡូក្រាមប៉ុណ្ណោះ។ ដើម្បីឲ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាម លើផ្ទៃដី ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវនៅឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គិសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អ គួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ ដើម។ សម្រាប់ស្រូវពង្រោះ បរិមាណគ្រាប់ពូជដែលចាំបាច់គឺ ៦០ គីឡូក្រាមក្នុងមួយហិកតា។ គួររៀបចំដីឲ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រោះ។ ការភ្ជួររាស់ គួរតែធ្វើឲ្យបាន ២-៣ សារ ជាការល្អប្រសើរ។ ប្រសិនបើស្រែអាចបញ្ចូលបញ្ចេញទឹកបាន បន្ទាប់ពីស្ទូង ឬព្រោះបាន ២០ ថ្ងៃ ត្រូវបញ្ចេញទឹកឲ្យអស់ពីក្នុងស្រែក្នុងរយៈពេល ២-៤ ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឲ្យស្រូវកាន់តែបែកគុម្ពល្អ។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ និងមិនបណ្តាលឲ្យមានការថយចុះ ឬបាត់បង់គុណភាពដទៃទៀតឡើយ។ គួរដាក់ជីអាសូត ៣ ដង ក្នុងមួយវដ្តជីវិតរបស់ស្រូវ។ បាចទ្រាប់បាតមុនពេលស្ទូង ដោយប្រើជីធម្មជាតិ ៥ តោន (២០







រទេះ) ក្នុង ១ ហិកតា និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី ១។ បរិមាណជីបាចបំប៉នលើកទីមួយ និងលើកទីពីរ ត្រូវអនុលោមតាមតារាងទី ១ ហើយពេលវេលានៃការបាច ត្រូវអនុលោមតាមតារាងទី ២។




**តារាងទី ១**

| ក្រុមដី | ស្រូវកណ្តាល និងស្រូវធ្ងន់ (ស្រូវវស្សា) | | | | |
|---|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉នអ៊ុយរ៉េ (គ.ក្រ/ហាត) | |
| | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូ ០-០-៦០ | លើកទី ១ | លើកទី ២ |
| ដីព្រៃខ្មែរ | ១០ | ២០ | ៤០ | ២០ | ១០ |
| ដីប្រទះឡាង | ១០ | ៥០ | ២៥ | ២៥ | ២៥ |
| ដីបាកាន ឬអូររាង | ២៥ | ២៥ | ២៥ | ៥០ | ២៥ |
| ដីទូលសំរោង | ២៥ | ៥០ | ០ | ២៥ | ២៥ |
| ដីគោគត្រប់ | ១០ | ៥០ | ៥០ | ៤០ | ៣៥ |
| ដីកំពង់សៀម | ៣០ | ០ | ០ | ៤០ | ៣០ |
| ដីកៀនស្វាយ | ជាដីតាមមាត់ច្រាំងទន្លេ និងជម្រាលពីច្រាំងទន្លេសមស្របសម្រាប់ស្រូវស្រាល | | | | |
| ដីក្រគរ | ជាដីលិចទឹករយៈពេលយូរ ដែលកសិករធ្វើស្រូវឡើងទឹក ឬប្រដេញទឹក | | | | |
| ដីក្បាលពោធិ | | | | | |

**តារាងទី ២**

| ពេលវេលាសាប | បំប៉នលើកទី ១ | បំប៉នលើកទី ២ |
|---|---|---|
| ១-៣១ មិថុនា | ៣០ ថ្ងៃក្រោយស្ទូង | ១-៥ តុលា |
| ១-១៥ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ៦-១០ តុលា |
| ១៦-៣០ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១១-១៥ តុលា |

## ការប្រមូលផល និងទុកដាក់

- ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អ គឺនៅពេលដែលកួរស្រូវមានគ្រាប់ចាប់ពីពាក់កណ្តាលកួរឡើងទៅមានពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្តាលកួរចុះក្រោមមានពណ៌លឿងទុំស្រាល ហើយគ្រាប់ស្អកវិញមានពណ៌ស្លាបសេកចាស់។
- គេអាចហាលសម្ងួតស្រូវនៅលើកន្ទេល សំណាញ់មុង តង់កៅស៊ូ និងលានស៊ីម៉ង់ត៍ គឺមិនបណ្តាលឲ្យគុណភាពគ្រាប់ស្រូវ ឬគ្រាប់ស្រូវពូជខុសគ្នាឡើយ។ កម្រាស់គ្រាប់ស្រូវដែលសមស្របសម្រាប់ការហាលសម្ងួត គឺ ២-៣ ស.ម ដែលកម្រាស់គ្រាប់ និងសភាពពន្លឺថ្ងៃគឺជាកត្តាចម្បងក្នុងការកំណត់រយៈពេលហាល និងគុណភាពគ្រាប់ស្រូវ៖
  - ថ្ងៃស្រឡះល្អ ហាលតែ ១ ថ្ងៃ ប៉ុណ្ណោះ ដោយកន្លះម៉ោងរឺម្តង។
  - ថ្ងៃស្រឡះបង្គួរ ហាលសម្ងួតរយៈពេល ២ ថ្ងៃ ដោយមួយម៉ោងរឺម្តង។
  - ថ្ងៃមិនស្រឡះ គេត្រូវហាលរហូតដល់ ៣ ថ្ងៃ ដោយ ២ ម៉ោង រឺម្តង។



- គ្រាប់ពូជត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងឲ្យជិត រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាច់ដោយឡែកពីគ្រាប់ស្រូវចំណី នៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។
- ផលស្រូវដែលប្រមូលបាន ត្រូវទុកដាក់ក្នុងជង្រុកឲ្យបានល្អ ដោយការពារកុំឲ្យសត្វកណ្តុរ មាន់ ទាស៊ី និងមិនឲ្យទទឹក។




សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្សរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh